## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៨៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន និង អនុគណៈកម្មាធិការរបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦២១/៤៩៩ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- យោងតាមសំណើរបស់ក្រសួងមុខងារសាធារណៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតលេខាធិការដ្ឋាន និងអនុគណៈកម្មាធិការនានា នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ "គ.ក.រ" ដើម្បីរៀបចំ គាំទ្រ និងសម្របសម្រួលដល់ការងារកែទម្រង់រដ្ឋបាលសាធារណៈ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់ ៖

- ភារកិច្ច និងរចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- ភារកិច្ច សមាសភាព និងរបៀបរបបការងាររបស់អនុគណៈកម្មាធិការនានានៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តក្នុងក្របខណ្ឌនៃការងារកំណែទម្រង់រដ្ឋបាលសាធារណៈ ។

## ជំពូកទី២
## លេខាធិការដ្ឋានរបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

**មាត្រា៤ .-**

លេខាធិការដ្ឋានរបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ សរសេរជាអក្សរកាត់ថា "ល.គ.ក.រ" ជាសេនាធិការរបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងការសម្របសម្រួលដល់ដំណើរការការងាររបស់អនុគណៈកម្មាធិការនានា ដើម្បីជំរុញ និងត្រួតពិនិត្យការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ។

ល.គ.ក.រ មានភារកិច្ចដូចតទៅ៖

- សម្របសម្រួលកិច្ចការប្រចាំថ្ងៃរបស់ គ.ក.រ
- ផ្តល់ការគាំទ្រ និងកិច្ចសហការជាមួយអនុគណៈកម្មាធិការនៃ គ.ក.រ ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា ដើម្បីរៀបចំគោលនយោបាយ កម្មវិធី យុទ្ធសាស្ត្រ និងផែនការសកម្មភាព ព្រមទាំងលិខិតបទដ្ឋានគតិយុត្ត និងឯកសារនានា ដែលពាក់ព័ន្ធនឹងការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីសុំការពិនិត្យសម្រេចពី គ.ក.រ
- ជួយគាំទ្រ និងលើកយោបល់ដើម្បីធានាប្រសិទ្ធភាពការងាររបស់អនុគណៈកម្មាធិការនានានៃ គ.ក.រ តាមការចាំបាច់
- រៀបចំកិច្ចប្រជុំនានារបស់ គ.ក.រ និងសម្របសម្រួលរៀបចំការពិគ្រោះយោបល់ទាំងឡាយដែលពាក់ព័ន្ធដល់ការកែទម្រង់រដ្ឋបាលសាធារណៈ ស្របតាមការណែនាំរបស់ គ.ក.រ
- ផ្សព្វផ្សាយពីគោលនយោបាយ កម្មវិធី យុទ្ធសាស្ត្រ និងផែនការសកម្មភាព ព្រមទាំងសមិទ្ធផលនានានៃកំណែទម្រង់រដ្ឋបាលសាធារណៈ
- ធ្វើរបាយការណ៍បូកសរុប និងវាយតម្លៃពីវឌ្ឍនភាពការងាររបស់ គ.ក.រ ទៅតាមកាលកំណត់
- បំពេញភារកិច្ចផ្សេងទៀតតាមការកំណត់របស់ គ.ក.រ ។

**មាត្រា៥ .-**

ល.គ.ក.រ ត្រូវដឹកនាំដោយប្រធាន ១រូប អមដោយអនុប្រធាន មួយចំនួន តាមការចាំបាច់ ។

ប្រធានលេខាធិការដ្ឋាន ត្រូវតែងតាំងពីអនុរដ្ឋលេខាធិការ ១រូប នៃក្រសួងមុខងារសាធារណៈ ។

អនុប្រធានទី១ នៃលេខាធិការដ្ឋាន គឺជាអគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ ។

ប្រធាននិងអនុប្រធានលេខាធិការដ្ឋានត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធាន គ.ក.រ ។

**មាត្រា៦ .-**

មន្ត្រីបម្រើការងារក្នុង ល.គ.ក.រ ត្រូវជ្រើសរើសពីមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាដែលមានសមត្ថភាពជំនាញ និងបទពិសោធន៍ នៃក្រសួងមុខងារសាធារណៈ ស្របតាមតម្រូវការការងារជាក់ស្តែង ។

**មាត្រា៧ .-**

ល.គ.ក.រ មានរចនាសម្ព័ន្ធ ដូចខាងក្រោម៖

១. អង្គភាពគាំទ្រផ្នែកគោលនយោបាយ

២. អង្គភាពគាំទ្រផ្នែកបច្ចេកទេស និងព័ត៌មានវិទ្យា

៣. អង្គភាពទំនាក់ទំនងសហប្រតិបត្តិការ

៤. អង្គភាពត្រួតពិនិត្យ និងវាយតម្លៃ

៥. អង្គភាពរដ្ឋបាល សរុប និងគណនេយ្យ

អង្គការលេខរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៨ .-**

អង្គភាពនីមួយៗនៃ ល.គ.ក.រ ត្រូវដឹកនាំដោយប្រធាន ១រូប និងអនុប្រធានមួយចំនួន តាមការចាំបាច់។

ប្រធាន និងអនុប្រធានអង្គភាព ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធាន គ.ក.រ ។

តួនាទី និងភារកិច្ចរបស់អង្គភាពនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធាន គ.ក.រ ។

## ជំពូកទី៣
## អនុគណៈកម្មាធិការនានារបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

**មាត្រា៩ .-**

គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈមានអនុគណៈកម្មាធិការមួយចំនួនដូចខាងក្រោម៖

១- អនុគណៈកម្មាធិការកែទម្រង់រចនាសម្ព័ន្ធ ប្រព័ន្ធបៀវត្ស និងបន្ទុកបុគ្គលិករបស់ក្រសួង ស្ថាប័ន

២- អនុគណៈកម្មាធិការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ និងបៀវត្ស

៣- អនុគណៈកម្មាធិការកសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ

៤- អនុគណៈកម្មាធិការកែលម្អ និងវាយតម្លៃសេវាសាធារណៈ

គ.ក.រ អាចបង្កើតអនុគណៈកម្មាធិការបន្ថែម តាមការចាំបាច់។

**មាត្រា១០ .-**

អនុគណៈកម្មាធិការនីមួយៗមានសមាសភាពដូចខាងក្រោមៈ

**១. អនុគណៈកម្មាធិការកែទម្រង់រចនាសម្ព័ន្ធ ប្រព័ន្ធបៀវត្ស និងបន្ទុកបុគ្គលិករបស់ក្រសួង ស្ថាប័ន**

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ | ប្រធាន |
| - រដ្ឋលេខាធិការប្រចាំការក្រសួងមុខងារសាធារណៈ | អនុប្រធាន |
| - អនុរដ្ឋលេខាធិការ | សមាជិក |
| - ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន អង្គភាពចំណុះក្រសួងមុខងារសាធារណៈ | សមាជិក |
| - មន្ត្រីជំនាញមួយចំនួន | សមាជិក |

**២. អនុគណៈកម្មាធិការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ និងបៀវត្ស**

| | |
|---|---|
| - រដ្ឋលេខាធិការ/អនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | ប្រធាន |
| - អនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | អនុប្រធាន |
| - ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន អង្គភាពចំណុះក្រសួងមុខងារសាធារណៈ | សមាជិក |
| - មន្ត្រីជំនាញមួយចំនួន | សមាជិក |

**៣. អនុគណៈកម្មាធិការកសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ**

| | |
|---|---|
| - រដ្ឋលេខាធិការ/អនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | ប្រធាន |

- អនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ អនុប្រធាន
- ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន អង្គភាពចំណុះក្រសួងមុខងារសាធារណៈ សមាជិក
- មន្ត្រីជំនាញមួយចំនួន សមាជិក

៤. អនុគណៈកម្មាធិការកែលម្អ និងវាយតម្លៃសេវាសាធារណៈ

- រដ្ឋលេខាធិការ/អនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ ប្រធាន
- អនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ អនុប្រធាន
- ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន អង្គភាពចំណុះក្រសួងមុខងារសាធារណៈ សមាជិក
- មន្ត្រីជំនាញមួយចំនួន សមាជិក

សមាសភាពជាក់ស្តែងរបស់ប្រធាន អនុប្រធាន និងសមាជិកនៃអនុគណៈកម្មាធិការនីមួយៗ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធាន គ.ក.រ ។

**មាត្រា១១ .-**

អនុគណៈកម្មាធិការកែទម្រង់រចនាសម្ព័ន្ធ ប្រព័ន្ធបៀវត្ស និងបន្ទុកបុគ្គលិករបស់ក្រសួង ស្ថាប័ន មានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ ប្រព័ន្ធបៀវត្ស និងចំណាយបន្ទុកបុគ្គលិករបស់ក្រសួង ស្ថាប័ន ក្នុងវិស័យសាធារណៈ
- សិក្សា និងវិភាគរចនាសម្ព័ន្ធ ទំហំការងារ ចំនួនមន្ត្រីរាជការ និងចំណាយបន្ទុកបុគ្គលិករបស់ក្រសួង ស្ថាប័ន ក្នុងវិស័យសាធារណៈ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- កសាងឯកសារមូលដ្ឋានសម្រាប់ការវិភាគមុខងារ ការពិពណ៌នាមុខតំណែងមន្ត្រីរាជការរបស់ក្រសួង ស្ថាប័ន នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ដឹកនាំ ការពិភាក្សា និងការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា ដើម្បីកំណត់ពីគោលការណ៍ និងវិធីសាស្ត្រ សម្រាប់ការរៀបចំ និងការកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការរៀបចំយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការប្រើប្រាស់រចនាសម្ព័ន្ធ ប្រព័ន្ធបៀវត្ស ប្រព័ន្ធលាភការ និងរបបគាំពារសង្គមផ្សេងទៀតសម្រាប់កំណែទម្រង់ពាក់ព័ន្ធដល់ការចំណាយបន្ទុកបុគ្គលិកក្នុងវិស័យសាធារណៈ
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់ គ.ក.រ ។

**មាត្រា១២ .-**

អនុគណៈកម្មាធិការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ និងបៀវត្ស មានភារកិច្ចដូចខាងក្រោម៖

- កសាងគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹង ការគ្រប់គ្រងមន្ត្រីរាជការ និងបៀវត្ស ប្រព័ន្ធលាភការ និងរបបគាំពារសង្គមផ្សេងទៀត
- ជម្រុញការអភិវឌ្ឍ និងការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ និងបៀវត្ស ប្រព័ន្ធលាភការ និងរបបគាំពារសង្គមផ្សេងទៀត តាមប្រព័ន្ធព័ត៌មានវិទ្យា
- រៀបចំយន្តការគាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការគ្រប់គ្រងមន្ត្រីរាជការ និងបៀវត្ស ប្រព័ន្ធលាភការ និងរបបគាំពារសង្គមផ្សេងទៀត នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់ គ.ក.រ ។

**មាត្រា១៣ .-**

អនុគណៈកម្មាធិការកសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ មានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការជ្រើសរើស ការបណ្តុះបណ្តាល ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ

- កសាងយុទ្ធសាស្ត្រ កម្មវិធី ផែនការសកម្មភាព សម្រាប់ការបណ្តុះបណ្តាលមន្ត្រីរាជការសាធារណៈក្នុងរយៈពេលមធ្យម និងរយៈពេលវែង
- សហការជាមួយស្ថាប័ន គ្រឹះស្ថានបណ្តុះបណ្តាលនានា និងដៃគូអភិវឌ្ឍន៍ រៀបចំផែនការ កម្មវិធី វគ្គសិក្សា ដើម្បីឆ្លើយតបនឹងសំណូមពរ តម្រូវការ ក្នុងការលើកកម្ពស់សមត្ថភាពជំនាញ និងសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីរាជការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់ គ.ក.រ ។

**មាត្រា១៤ .-**

អនុគណៈកម្មាធិការកែលម្អ និងវាយតម្លៃសេវាសាធារណៈ មានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងសេវាសាធារណៈ
- កសាងយុទ្ធសាស្ត្រ កម្មវិធី ផែនការសកម្មភាព សម្រាប់ការលើកកម្ពស់ ការកែលម្អសេវាសាធារណៈរបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- រៀបចំយន្តការនានាដើម្បីគាំទ្រដល់ដំណើរការនៃការកែលម្អ និងការវាយតម្លៃសេវាសាធារណៈរបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ពិនិត្យ និងផ្តល់យោបល់លើការវាយតម្លៃ និងការទទួលស្គាល់ក្រសួង ស្ថាប័ន និងអង្គភាពផ្តល់សេវាសាធារណៈដែលមានស្នាដៃ
- រៀបចំប្រព័ន្ធវាយតម្លៃស្នាដៃផ្អែកលើសមិទ្ធកម្មរបស់មន្ត្រីម្នាក់ៗ ដែលបម្រើការងារក្នុងរដ្ឋបាលសាធារណៈនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់ គ.ក.រ ។

**មាត្រា១៥ .-**

អនុគណៈកម្មាធិការនីមួយៗត្រូវបំពេញការងារតាមការចាត់ចែងរបស់ប្រធានអនុគណៈកម្មាធិការ។

អនុប្រធាន និងសមាជិកនៃអនុគណៈកម្មាធិការនីមួយៗ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានអនុគណៈកម្មាធិការ ។

**មាត្រា១៦ .-**

អនុគណៈកម្មាធិការនីមួយៗត្រូវមានកិច្ចប្រជុំប្រចាំខែ ។

របៀបវារៈនៃកិច្ចប្រជុំរបស់អនុគណៈកម្មាធិការនីមួយៗ អាស្រ័យទៅលើការកំណត់របស់ប្រធានអនុគណៈកម្មាធិការ ឬផ្អែកតាមការណែនាំរបស់ប្រធានគ.ក.រ ។

កិច្ចប្រជុំរបស់អនុគណៈកម្មាធិការនីមួយៗអាចយកជាការបាន លុះត្រាតែមានវត្តមានសមាជិកចូលរួមកិច្ចប្រជុំលើសពីពាក់កណ្តាលនៃចំនួនសមាជិកអនុគណៈកម្មាធិការទាំងមូល ។

**មាត្រា១៧ .-**

អនុគណៈកម្មាធិការនីមួយៗ អាចអញ្ជើញមន្ត្រីជំនាញ ឬអ្នកពាក់ព័ន្ធនានា ដើម្បីចូលរួមកិច្ចប្រជុំតាមការចាំបាច់។

មន្ត្រីជំនាញ ឬអ្នកពាក់ព័ន្ធដែលចូលរួមកិច្ចប្រជុំខាងលើនេះ មានសិទ្ធិផ្តល់យោបល់ ប៉ុន្តែពុំមានសិទ្ធិអនុម័តលើសេចក្តីសម្រេចរបស់កិច្ចប្រជុំបានឡើយ។

**មាត្រា១៨ .-**

រាល់ការសម្រេចរបស់អនុគណៈកម្មាធិការក្នុងការផ្តល់យោបល់និងអនុសាសន៍នានាជូន គ.ក.រ ត្រូវធ្វើឡើងដោយមានការឯកភាពគ្នា ផ្អែកលើសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិករបស់អនុគណៈកម្មាធិការ ដែលមានវត្តមានក្នុងកិច្ចប្រជុំ។

**មាត្រា១៩ .-**

រាល់កិច្ចប្រជុំរបស់អនុគណៈកម្មាធិការនីមួយៗ ត្រូវមានកំណត់ហេតុកិច្ចប្រជុំដែលត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ។

អនុគណៈកម្មាធិការនីមួយៗ ត្រូវរៀបចំ និងផ្ញើរបាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំនីមួយៗ និងរបាយការណ៍ប្រចាំខែជូនប្រធាន គ.ក.រ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា២០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា២១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១៤រោច ខែ ជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ព្រុំ សុខា**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៨៣ អនក្រ.បក
ចុះថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ២០២១

## អង្គភាពលេខ
## លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (ល.គ.ក.រ)

- ប្រធានលេខាធិការដ្ឋាន
  - អនុប្រធានលេខាធិការដ្ឋាន
    - អង្គភាព គាំទ្រផ្នែកគោលនយោបាយ
    - អង្គភាព គាំទ្រផ្នែកបច្ចេកទេស និងព័ត៌មានវិទ្យា
    - អង្គភាព ទំនាក់ទំនងសហប្រតិបត្តិការ
    - អង្គភាព ត្រួតពិនិត្យ និងវាយតម្លៃ
    - អង្គភាព រដ្ឋបាល សរុប និងគណនេយ្យ